# របាំបុកល័ក្ត

ពិធីអាពាហ៍ពិពាហ៍ ជាព្រឹត្តិការណ៍ប្រចាំជីវិតដ៏សំខាន់មួយសម្រាប់មនុស្សគ្រប់រូប។ នាបុរាណកាល ពិធីអាពាហ៍ពិពាហ៍ខ្មែរ ធ្លាប់បានប្រារព្ធធ្វើឡើងនៅក្នុងរយៈពេល៧ថ្ងៃ ៧យប់។ ក្រោយមក គេធ្វើតែ៣ថ្ងៃ ៣យប់ ហើយនៅនាពេលបច្ចុប្បន្ននេះ គ្រួសារខ្លះធ្វើតែ១ថ្ងៃតែប៉ុណ្ណោះ។ មួយថ្ងៃ បីថ្ងៃ ឬប្រាំពីរថ្ងៃ គេតែងតែរៀបចំឱ្យមានពិធីផ្សេងៗ ដូចជាពិធីចូលរោង ពិធីហែកូនកំលោះ ពិធីកាត់សក់ ពិធីធ្វើធ្មេញ ពិធីចងដៃ ពិធីផ្ទឹម ពិធីបង្វិលពពិល ពិធីរាំដាវ ពិធីសារកន្សែល និងពិធីគោងស្នែជាដើម។

ពិធីអាពាហ៍ពិពាហ៍ទាំងមូល កំដរដោយវង់តន្ត្រីអាពាហ៍ពិពាហ៍ឬហៅថាវង់ភ្លេងការ ទាំងនៅពេលធ្វើពិធី ឬគ្រាន់តែកំដររោងឱ្យមានភាពអធឹកអធម កុំឱ្យស្ងាត់។ នៅតាមជនបទស្រែចម្ការ គេចាក់ភ្លេងការទាំងនេះតាមគ្រឿងបំពងសំឡេងដែលគេចងនៅលើដើមឈើឱ្យឮសូរបានឆ្ងាយ ដើម្បីប្រកាសផ្សព្វផ្សាយឱ្យអ្នកជិតខាង អ្នកស្រុកអ្នកភូមិផងរបងជាមួយ ដឹងឮអំពីចំណងអាពាហ៍ពិពាហ៍នៃគូស្វាមីភរិយាថ្មី។

ប្រពៃណីបុរាណខ្មែរ មានការនិយមធ្មេញខ្មៅរលើប ដូចដែលយើងឃើញជាពិសេសស្ត្រីចាស់ៗគាត់ពីសាម្លស្លា ដែលធ្វើឱ្យធ្មេញរបស់គាត់មានពណ៌ខ្មៅ។ នៅក្នុងតំបន់ខ្លះនៃប្រទេសកម្ពុជា គេនៅមានធ្វើពិធីនិងរាំរបាំបុកល័ក្តនៅក្នុងពិធិអាពាហ៍ពិពាហ៍ ដែលក្នុងនោះបុរសអុំទូកទៅរកល័ក្ត ដើម្បីយកមកធ្វើធ្មេញឱ្យនារីដែលខ្លួនស្រឡាញ់។

របាំបុកល័ក្ត ចែកចេញជាបីវគ្គ៖ វគ្គទី១ បុរសអុំទូកទៅរកល័ក្ត, វគ្គទី២ ការបុកល័ក្តនិងវគ្គទី៣ ការសប្បាយរីករាយនឹងកិច្ចការដែលគេបានធ្វើនិងបញ្ចប់។ របាំប្រពៃណីខ្មែរខ្លះកំដរដោយតន្ត្រីមហោរី ចំណែកឯរបាំបុកល័ក្ត កំដរដោយតន្ត្រីអាពាហ៍ពិពាហ៍ជាមួយនឹងពាក្យពេចន៍រៀបរាប់អំពីធម្មជាតិនិងជីវិតរស់នៅរបស់ខ្មែរសេចក្តីស្រឡាញ់របស់បុរសចំពោះនារី ដែលខ្លួនអុំទូកទៅរកល័ក្តដើម្បីបំពេញចិត្ត និងដើម្បីថែរក្សាប្រពៃណីទំនៀមទម្លាប់បុកល័ក្តនិងធ្វើធ្មេញទៀតផង។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

## អុំទូក

| | | |
|---|---|---|
| ១. បងអុំទូកទៅ | សំដៅត្រើយនាយ | (ស្ទួន) |
| គាស់ទឹកៗឡើងខ្វាយ[១] | សប្បាយពេកក្រៃ | (ស្ទួន)ៗ |
| ២. ឥឡូវបានល័ក្ត | យកផ្ញើស្រីថ្លៃ | (ស្ទួន) |
| បុកធ្ញើៗធ្មេញស្រី[២] | ស្រីស្រស់ព្រលឹង | (ស្ទួន)ៗ |

## បុកល័ក្ត

| | | |
|---|---|---|
| ១. លេងភ្លេងបុកល័ក្ត | ទទាក់មេឡា | (ស្ទួន) |
| ធ្វើធ្មេញៗកូនចៅ | បំពេញល័ក្តស្រី | (ស្ទួន)។ |
| ២. ម៉ុមអើយស្រីម៉ុម | ម៉ុមអើយស្រីម៉ុម | (ស្ទួន) |
| ថ្ពាល់ដូចៗត្រប់ទុំ | ដៃម៉ុមលាយល័ក្ត | (ស្ទួន)។ |
| ៣. បាតដៃខ្នងដៃ | សុទ្ធតែត្រដាក់[៣] | (ស្ទួន) |
| ដៃនាងៗលាយល័ក្ត | ដាក់លំទ្រូងបង | (ស្ទួន)។ |

## ឯកសារពិគ្រោះ


*Musique Khmère*. (1969). Phnom Penh: Imprimerie Sangkum Réastr Niyum.

Sam, Chan Moly, Nguon, Sam Ath, and Sam, Sam-Ang. (1998). *Khmer Folk Dance* (2nd ed.). Washington, DC: Cambodian Network Council.

Sam, Sam-Ang. (2002). *Musical Instruments of Cambodia*. Osaka, Japan: National Museum of Ethnology.


[១] អ្នកច្រៀងខ្លះច្រៀងថា «គាស់ទឹកៗបែកខ្វាយ» (Sam, Nguon, and Sam 1998: 123)

[២] អ្នកច្រៀងខ្លះច្រៀងថា «យកធ្ញើៗធ្មេញជ័យ» (Sam, Nguon, and Sam 1998: 123)

[៣] អ្នកច្រៀងខ្លះច្រៀងថា «ត្រជំត្រដាក់» (Sam, Nguon, and Sam 1998: 123)

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង







អត្ថបទដោយៈ បណ្ឌិត សំ សំអាង